ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៚៚៚ 🕮 ៚៚៚

សាលាដំបូងខេត្តសៀមរាប

សាលក្រមព្រហ្មទណ្ឌ
លេខ: ៣៦(ជ)/២៨៨
ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣
-សំណុំរឿងព្រហ្មទណ្ឌលេខ: ១១៧៤
ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២
-សំណុំរឿងជំនុំជម្រះលេខ: ៩១
ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជំនុំជម្រះជាសាធារណៈ សាលសវនាការលេខ ក១ អគារក នៃសាលាដំបូងខេត្តសៀមរាប នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ប្រាំបី និងសាមសិបនាទីព្រឹក ដែលមានសមាសភាពចូលរួមដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ឋានៈចៅក្រម ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក ឋានៈចៅក្រម ជាចៅក្រមប្រឹក្សា
លោក ឋានៈចៅក្រម ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូង

ដើម្បីជំនុំជម្រះលើ ៖ សំណុំរឿងព្រហ្មទណ្ឌលេខ: ១១៧៤ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ២០២២ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] គឹមហួរ ភេទប្រុស កើតថ្ងៃទី០១ ខែសីហា ឆ្នាំ២០០១ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តព្រៃវែង ទីលំនៅមុនពេលឃាត់ខ្លួននៅភូមិឈូកស ឃុំឃុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី៦ មុខរបរកម្មករឡេឥដ្ឋ នៅលីវ ឪពុកឈ្មោះ [redacted] ហឿន (រស់) ម្តាយឈ្មោះ [redacted] និមល (រស់) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ (ក្នុងឃុំ)

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧៥៩យខ/៣ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២២។

២- ឈ្មោះ [redacted] សុខ ភេទប្រុស កើតនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៥ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តសៀមរាប ទីលំនៅមុនពេលឃាត់ខ្លួននៅភ[redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី៨ មុខរបរ កសិករ នៅលីវ ឪពុកឈ្មោះ [redacted] វើន (រស់) ម្តាយឈ្មោះ [redacted] ផុង (រស់) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ (ក្នុងឃុំ)

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧៦០យខ/៣ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២២។



Scanned with CamScanner

៣- ឈ្មោះ [redacted] តៅ ភេទប្រុស កើតនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៤ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តសៀមរាប មុខរបរ មិនពិតប្រាកដ នៅលីវ ឪពុកឈ្មោះ [redacted] ទាច (រស់) ម្ដាយឈ្មោះ [redacted] ហាប់ (ស្លាប់) ។ (គេចខ្លួន)

៤- ឈ្មោះ [redacted] ស៊ីមែតុង ហៅ តុង ភេទប្រុស កើតនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៧ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ន នៅ[redacted] ខេត្តសៀមរាប មុខរបរ មិនពិតប្រាកដ នៅលីវ ឪពុកឈ្មោះ [redacted] ម៉ៅ (រស់) ម្ដាយឈ្មោះ [redacted] តេនា (រស់) ។(គេចខ្លួន)

ជាប់ចោទពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅចំណុចភ្លោងទ្វារទន្លេអុំ ស្ថិតនៅភូមិក្រវ៉ាន់ សង្កាត់នគរធំ ខេត្តសៀមរាប កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ។

ដោយមានលោក ហុង ប៊ុនហាវ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សុខ ។

លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ស៊ីមែតុង និងឈ្មោះ [redacted] តៅ និងឈ្មោះ [redacted] គឹមហួរ ។

**អង្គហេតុកើតឡើងមានដូចតទៅ:**

កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ១៨ និង ០០ នាទី ស្ថិតនៅចំណុចភ្លោងទ្វារទន្លេអុំ ស្ថិតនៅភូមិក្រវ៉ាន់ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប មានជន៤នាក់មានឈ្មោះ [redacted] គឹមហួរ ភេទប្រុស អាយុ២១ឆ្នាំ ,ឈ្មោះ [redacted] សុខ ភេទប្រុស អាយុ ១៧ឆ្នាំ ,ឈ្មោះ [redacted] ស៊ីមែតុង ភេទប្រុស អាយុ ១៥ឆ្នាំ និងឈ្មោះ [redacted] តៅ ភេទប្រុស អាយុ ១៨ឆ្នាំ បានធ្វើសកម្មភាពជិះម៉ូតូដេញកាប់ជនរងគ្រោះ ឈ្មោះ [redacted] សុម៉ៃ ,ឈ្មោះ [redacted] សាយ ជិះម៉ូតូ១គ្រឿង ,ឈ្មោះ [redacted] កា និងឈ្មោះ [redacted] ឡូ ជិះម៉ូតូ១គ្រឿង។ នៅពេលកំពុងកើតហេតុនោះ ជនរងគ្រោះឈ្មោះ [redacted] សុម៉ៃ និងឈ្មោះ [redacted] សាយ បានជិះម៉ូតូគេច ចំណែកឈ្មោះ [redacted] កា និងឈ្មោះ ឡឹ ឡូ បានជិះម៉ូតូមកដល់ភ្លោងទ្វារទន្លេអុំ ក៏ត្រូវបានឈ្មោះ ជុង គឹមហួរ ជិះម៉ូតូឌុបឈ្មោះ [redacted] ស៊ីមែតុង បានតាមទាន់ ពេលនោះឈ្មោះ [redacted] ស៊ីមែតុង បានយកម្ជូកសុវត្ថិភាព វាយទៅលើជនរងគ្រោះឈ្មោះ [redacted] កា ត្រូវចំពីក្រោយ ចំនួន ២មួក បណ្ដាលឲ្យម៉ូតូជនរងគ្រោះវ៉ែចង្កូតទៅ បុកនឹងភ្លោងទ្វារទន្លេអុំ(ធ្វើពីថ្មភក់)ប្រកចូលប្រាសាទបាយ័ន ពេញមួយទំហឹងបណ្ដាលឲ្យជនរងគ្រោះទាំងពីនាក់ស្លាប់នៅនឹងកន្លែងកើតហេតុ ចំណែកជនបង្កបានជិះម៉ូតូគេចខ្លួន។ ក្រោយពីកើតហេតុខាងលើនេះរួចមក គ្រួសារជនរងគ្រោះបានដឹងរឿងហេតុការណ៍ បានទៅដាក់ពាក្យបណ្ដឹងនៅសមត្ថកិច្ច ហើយសមត្ថកិច្ចបានធ្វើការស្រាវជ្រាវ កំណត់អត្តសញ្ញាណ និងធ្វើការឃាត់ខ្លួនលើឈ្មោះ [redacted] គឹមហួរ និងឈ្មោះ [redacted] សុខ ចំណែកឈ្មោះ [redacted] ស៊ីមែតុង និងឈ្មោះ [redacted] តៅ បានរត់គេចខ្លួនបាត់ទៅ។

**ដើមបណ្ដឹងរដ្ឋប្បវេណី**

១- ឈ្មោះ [redacted] សុម៉ៃ ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ។



Scanned with CamScanner

២- ឈ្មោះ [redacted] សាយ ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិសំបួរ ឃុំរើល ស្រុកពួក ខេត្តសៀមរាប ។

៣- ឈ្មោះ [redacted] ស្រីម៉ៅ ភេទស្រី អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិសំបួរ ឃុំរើល ស្រុកពួក ខេត្តសៀមរាប ។

៤- ឈ្មោះ [redacted] ហួន ភេទស្រី អាយុ ៥០ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិសំបួរ ឃុំរើល ស្រុកពួក ខេត្តសៀមរាប ។

បានឃើញៈ របាយការណ៍សំយោគលេខ ៣០៦/២០២២ ព្រ.ទ.ក.ធ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០២២ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប ។

បានឃើញៈ ដីកាសន្និដ្ឋានស្ថាពរលេខៈ ៦៤អយក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ របស់តំណាង អយ្យការអមសាលាដំបូងខេត្តសៀមរាប ។

បានឃើញៈ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ លេខៈ ៥៩៦ពស.ព្រទ/ឈ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ។

បានឃើញៈ ដីកាចាត់តាំងក្រុមប្រឹក្សាចៅក្រមជំនុំជម្រះ លេខៈ ០៨៦ពស.ព្រជ(ក)ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។

**នាពេលសវនាការ**

- ជនជាប់ចោទឈ្មោះ [redacted] គឹមហួរ បានឆ្លើយថា សមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទីមិនចាំ ខែតុលា ឆ្នាំ ២០២២ វេលាម៉ោងប្រហែលម៉ោង ១រសៀល ស្ថិតនៅចំណុចភូមិឈូកស ឃុំយុនរាម ស្រុកបន្ទាយស្រី ខេត្ត សៀមរាប នៅកន្លែងធ្វើការឡេតជ្ជ។ កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ១៥ និង ០០ នាទី ខ្លួនបានចេញពីផ្ទះនៅភូមិឈូកស ឃុំយុនរាម ដោយមានគ្នាចំនួន ៤នាក់ មានឈ្មោះ តុង ភេទប្រុស អាយុប្រហែល ១៥ឆ្នាំ ចំណែកមនុស្សប្រុស ២នាក់ទៀត ខ្លួនមិនស្គាល់នោះទេ ជិះម៉ូតូចំនួន ២គ្រឿង ម៉ាក ឌ្រីមសង់ ពណ៌ខ្មៅ ដោយខ្លួនបើកឌុបឈ្មោះ តុង ជិះទៅដល់រង្វង់មូលស្រុកបន្ទាយស្រី អង្គុយប្រហែល ៣០ នាទី ផឹកស្រាបៀរអស់ម្នាក់ប្រហែល ២កំប៉ុង រួចក៏បាននាំគ្នាជិះបន្តទៅអង្គរវត្ត លុះនៅវេលាម៉ោងប្រហែល ១៨ និង ០០នាទី បានជិះដល់ចំណុចកសិណអង្គរខាងជើងឈៀងខាងកើតបានបន្តិចក្រោយមកមានបក្ខ ពួករបស់ខ្លួនចំនួន ៣នាក់ទៀត មានឈ្មោះ [redacted] រតនា ភេទប្រុស អាយុ១៣ឆ្នាំ ,ឈ្មោះ [redacted] សុខ ភេទប្រុស អាយុ ១៧ឆ្នាំ និងឈ្មោះ ទាច តៅ ភេទប្រុស អាយុ ១៨ឆ្នាំ ជិះម៉ូតូ២គ្រឿង ម៉ាកឌ្រីម ពណ៌ខ្មៅ ពេលទៅ ដល់បាននាំគ្នាអង្គុយលេងបានប្រហែលជិត ២០នាទី ស្រាប់តែមានមនុស្សប្រុសមានគ្នាចំនួន៤នាក់ ជិះម៉ូតូ ២គ្រឿងម៉ាកហុងដាឌ្រីម ជិះមកដល់ជិតចំណុចដែលពួកខ្លួនអង្គុយលេង ហើយខ្លួនបានឃើញអ្នកធ្លាប់ ស្គាល់គ្នាពេលដើរលេងពីមុនមកឈ្មោះ តុង បានហៅឲ្យខ្លួនបើកម៉ូតូទៅវាយពួកនោះ(ជនរងគ្រោះ) ដោយ ក្នុងនោះបក្ខពួកមានគ្នាចំនួន ៥នាក់ ជិះម៉ូតូចំនួន ៣គ្រឿង ដោយខ្លួនបើកម៉ូតូឌុបឈ្មោះ តុង ភេទប្រុស និងឈ្មោះ [redacted] សុខ ជិះម៉ូតូម្នាក់ឯង និងមនុស្សប្រុស ២នាក់ទៀត ខ្លួនមិនស្គាល់អត្តសញ្ញាណទេ ។ ពេល

ជិះឌុបគ្នាដល់កន្លែងកើតហេតុខាងលើ ស្រាប់តែពេលនោះឈ្មោះ គុង បានស្រែងថាកាប់វាទៅ ពេលនោះមនុស្សប្រុសចំនួន៤នាក់(ជនរងគ្រោះ)ខាងលើបាននាំគ្នាជិះម៉ូតូគេចតាមកស្សិណអង្គរទៅត្បូង ដល់ចំណុចកស្សិណអង្គរខាងត្បូងឈៀងខាងលិច មានផ្លូវបំបែក ពួកគេទាំង៤នាក់បានជិះម៉ូតូបែកផ្លូវគ្នា ដោយមនុស្សប្រុស ២នាក់ ជិះម៉ូតូ ១គ្រឿង ឌុបគ្នាគេចទៅទិសខាងត្បូង និងមនុស្សប្រុស ២នាក់ទៀត ជិះម៉ូតូម៉ាកឌ្រីមសង់ ស៊េរីឆ្នាំ២០១៨ បិទភ្លើង អត់ពាក់មួកសុវត្ថិភាពទាំង២នាក់ ជិះគេចទៅទិសខាងជើងកាត់តាមមុខអង្គរឃើញដូច្នោះ ពេលនោះពួកខ្លួនទាំង៥នាក់ បានជិះដេញទៅទិសខាងជើងជិតដល់ក្លោងទ្វារទន្លេអុំ ដោយពេលធ្វើសកម្មភាពបក្ខពួកខ្លួនឈ្មោះ គុង បានទាញមួកការពារពណ៌ខ្មៅ ប្រើដៃស្តាំវាយចំមនុស្សប្រុស (ជនរងគ្រោះ) ដែលអង្គុយខាងក្រោយត្រូវចំផ្នែកខាងក្រោយ ចំនួន ២មួក បណ្តាលឲ្យរ៉េចង្កូតម៉ូតូបុកក្លោងទ្វារទន្លេអុំយ៉ាងខ្លាំង រួចហើយពួកខ្លួនទាំង៥នាក់បាននាំគ្នាជិះហួសទៅមុខដល់ផ្លូវបំបែកមុខប្រាសាទលានជល់ដំរី បត់ស្តាំចាក់ទៅឃុំព្រះដាក់ ស្រុកបន្ទាយស្រី បាត់ទៅ ។ ខ្លួនមិនបានដេញវាយអ្នកណាទេ ។

- ជនជាប់ចោទឈ្មោះ [redacted] សុខ បានឆ្លើយថា សមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទីពុំចាំ ខែតុលា ឆ្នាំ២០២២ វេលាម៉ោងប្រហែលម៉ោង ៣រសៀល ស្ថិតនៅចំណុចម្តុំផ្សារបន្ទាយស្រី នៅស្រុកបន្ទាយស្រី ខេត្តសៀមរាប មូលហេតុដែលសមត្ថកិច្ចឃាត់ខ្លួន គឺសមត្ថកិច្ចបានប្រាប់ថា ខ្លួនបានជាប់ពាក់ព័ន្ធនឹងករណីកាប់គ្នានៅចំណុចរង្វង់មូលបន្ទាយស្រី ស្រុកបន្ទាយស្រី ខេត្តសៀមរាប និងពាក់ព័ន្ធនៅចំណុចក្លោងទ្វារទន្លេអុំ ស្ថិតនៅភូមិក្រវ៉ាន់ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប ដោយឈ្មោះ [redacted] រតនា ឆ្លើយដាក់ថា ខ្លួនបានទៅជាមួយវានៅចំណុចក្លោងទ្វារទន្លេអុំ ។ នៅអំឡុងថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ ខ្លួនមិនបានទៅចំណុចក្លោងទ្វារទន្លេអុំ ស្ថិតនៅភូមិក្រវ៉ាន់ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប ទេ និងពុំបានទៅជាមួយឈ្មោះ កែ រតនា ទេ ។ ខ្លួនមិនស្គាល់ឈ្មោះ គុង ឈ្មោះ [redacted] តៅ ទេ គឺខ្លួនស្គាល់តែឈ្មោះ [redacted] រតនា និងឈ្មោះ [redacted] គីមហួរ ប៉ុណ្ណោះ។ ចំពោះអង្គហេតុដែលតំណាងអយ្យការបានចោទប្រកាន់មកលើខ្លួន ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅចំណុចក្លោងទ្វាទន្លេអុំ ភូមិក្រវ៉ាន់ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ ខ្លួនមិនទទួលស្គាល់ទេ ។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] សុម៉ៃ ,ឈ្មោះ [redacted] សាយ ,ឈ្មោះ [redacted] កា និងឈ្មោះ [redacted] ឡូ ទេ។ ខ្លួនមិនដែលធ្លាប់មានទំនាស់ជាមួយអ្នកណាទេ ។ ពេលសមត្ថកិច្ចឃាត់ខ្លួន ដកហូតបានទូរស័ព្ទដៃម៉ាក VIVO ពណ៌ទឹកសមុទ្រ ចំនួន១គ្រឿង ។

- តាមអំណានចម្លើយជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុម៉ៃ បានឆ្លើយថា នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ៦ និង៣០នាទីល្ងាច ដោយពេលនោះខ្លួនបានណាត់គ្នាជាមួយឈ្មោះ [redacted] សាយ ឈ្មោះ [redacted] កា និងឈ្មោះ [redacted] ឡូ ដើម្បីទៅដើរលេងនៅអង្គរវត្ត ដោយខ្លួនបានជិះម៉ូតូមួយ គ្រឿងម៉ាក ហុងដាឌ្រីម ស៊េរីឆ្នាំ២០២១ ពណ៌ខ្មៅ ផ្លាកលេខ សៀមរាប 5175 ឌុបឈ្មោះ [redacted] សាយ ហើយឈ្មោះ [redacted] ឡូ ជិះម៉ូតូម៉ាកហុងដាឌ្រីម ស៊េរីឆ្នាំ២០១៥ ពណ៌ខ្មៅ មិនទាន់ផ្លាកលេខ ឌុបឈ្មោះ [redacted] កា។ បន្ទាប់មកពួកខ្លួនទាំង៤នាក់ធ្វើដំណើរទៅដើរលេងនៅអង្គរតូចដល់ចំណុចខាងត្បូងកស្សិណា



Scanned with CamScanner

អង្គរតូច ត្រង់រង្វង់មូលបានបត់ទៅទិសខាងកើត ចំណុចផ្លូវកែង ស្រាប់តែមានម៉ូតូ២គ្រឿង ឌុបគ្នាម្នាក់មួយគ្រឿង បានយកដៃវាយទៅលើឈ្មោះ កុយ កា ចំកខាងឆ្វេងបណ្ដាលឱ្យដួលម៉ូតូរបស់ឈ្មោះ [redacted] កា ហើយឈ្មោះ [redacted] កា បែកក្បាល និងបណ្ដាលឱ្យបែកអាវម៉ូតូខាងឆ្វេង និងរៀចចង្កឹះលេខម៉ូតូ បន្ទាប់មកខ្លួន និងឈ្មោះ [redacted] សាយ បានជួយលើកម៉ូតូដែលដួលនោះ ហើយឈ្មោះ [redacted] ឡូ បានពត់ចង្កឹះលេខម៉ូតូ ពេលនោះក្រុមម៉ូតូដែលបានវាយឈ្មោះ [redacted] កា នោះបានជិះត្រឡប់មកវិញ ហើយពួកវាបានស្រែកថា ដេញកាប់ពួកវាទៅ ពេលនោះ ខ្លួន និងឈ្មោះ [redacted] សាយ ភ័យខ្លាំងពេកក៏បានជិះម៉ូតូគេចរៀងៗខ្លួនយ៉ាងលឿន ហើយខ្លួនឌុប ឈ្មោះ [redacted] សាយ ទៅចូលកន្លែងជាងជួសជុលម៉ូតូ ចំណែកឈ្មោះ កុយ និងឈ្មោះ [redacted] ឡូ ខ្លួនពុំដឹងថា ពួកវាជិះម៉ូតូទៅទីណានោះទេ បានមួយសន្ទុះក្រោយមក ប្រហែលកន្លះម៉ោង ឈ្មោះ [redacted] សាយ បាន ទូរស័ព្ទទៅឈ្មោះ [redacted] សៀប ដែលត្រូវជាបងបង្កើតថា ឱ្យជួយទូរស័ព្ទទៅឈ្មោះ [redacted] កា ដោយសារ ឈ្មោះ ស៊ាប សាយ ពុំស្គាល់លេខទូរស័ព្ទ កុយ កា។ នៅពេលដែលឈ្មោះ [redacted] សៀប ទូរស័ព្ទទៅរកឈ្មោះ [redacted] កា ពេលនោះ ឈ្មោះ [redacted] សៀប បានប្រាប់ទៅឈ្មោះ [redacted] សាយ ថា មានមនុស្សស្រីលើកទូរស័ព្ទរបស់ឈ្មោះ [redacted] កា ហើយនិយាយថា ឈ្មោះ [redacted] កា និងឈ្មោះ [redacted] ឡូ បានបុកភ្លោងទ្វារទន្លេអុំ ស្លាប់បាត់ហើយ។ ខ្លួនមិនដែលធ្លាប់មានទំនាស់ជាមួយអ្នកណាទេ។ ហើយខ្លួនក៏ពុំដឹងថាឈ្មោះ [redacted] សាយ ឈ្មោះ [redacted] កា និងឈ្មោះ [redacted] ឡូ ធ្លាប់មានទំនាស់ជាមួយអ្នកណាដែរ ។ ខ្លួនសូមប្ដឹងទាមទារសំណងជំងឺចិត្ត ចំនួន ២.៥០០(ពីរពាន់ប្រាំរយ)ដុល្លាអាមេរិក ។

- ជនរងគ្រោះ និងជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាយ បានឆ្លើយថា នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ៦ និង ៣០នាទីល្ងាច ដោយពេលនោះខ្លួនបានណាត់គ្នាជាមួយឈ្មោះ [redacted] សុម៉ៃ ,ឈ្មោះ [redacted] កា និងឈ្មោះ [redacted] ឡូ ដើម្បីទៅដើរលេងនៅអង្គរវត្ត ដោយខ្លួនបានជិះម៉ូតូ មួយគ្រឿង ម៉ាកហុងដាឌ្រីម ស៊េរីឆ្នាំ២០២១ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ដោយឈ្មោះ [redacted] សុម៉ៃ ជាអ្នកឌុបខ្លួន ហើយឈ្មោះ [redacted] ឡូ ជិះម៉ូតូម៉ាកហុងដាឌ្រីម ស៊េរីឆ្នាំ២០១៥ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ឌុបឈ្មោះ [redacted] កា ។ បន្ទាប់មកពួកខ្លួនទាំង៤នាក់បានធ្វើដំណើរទៅដើរលេងនៅអង្គរតូច នៅពេលដែលធ្វើដំណើរដល់ចំណុចខាងត្បូងកស៊ិណអង្គរតូច ត្រង់រង្វង់មូលបានបត់ទៅទិសខាងកើត ចំណុចផ្លូវកែង ស្រាប់តែមានម៉ូតូ២គ្រឿង ឌុបគ្នាម្នាក់មួយគ្រឿង បានយកដៃវាយទៅលើឈ្មោះ [redacted] កា ចំកខាងឆ្វេងបណ្ដាលឱ្យដួលម៉ូតូរបស់ឈ្មោះ [redacted] កា ហើយឈ្មោះ [redacted] កា បានបែកក្បាល និងបណ្ដាលឱ្យបែកអាវម៉ូតូខាងឆ្វេង និងរៀចចង្កឹះលេខម៉ូតូ បន្ទាប់មកខ្លួន និងឈ្មោះ [redacted] សុម៉ៃ បានជួយលើកម៉ូតូដែលបានដួលនោះ ហើយឈ្មោះ [redacted] ឡូ បានពត់ចង្កឹះលេខម៉ូតូ ពេលនោះក្រុមម៉ូតូដែលបានវាយលើឈ្មោះ [redacted] កា នោះ បានជិះត្រឡប់មកវិញ ហើយពួកវាបានស្រែកថា ដេញកាប់ពួកវាទៅ! ពេលនោះខ្លួន និងឈ្មោះ [redacted] សុម៉ៃ ភ័យខ្លាំងពេកក៏បានជិះម៉ូតូគេចរៀងៗខ្លួនយ៉ាងលឿន ហើយឈ្មោះ [redacted] សុម៉ៃ ឌុបខ្លួន ចូលទៅកន្លែងជាងជួសជុលម៉ូតូ ចំណែកឈ្មោះ កុយ និងឈ្មោះ [redacted] ឡូ ខ្លួនពុំដឹងថាពួកវាជិះម៉ូតូទៅទីណានោះទេ។បានប្រហែលកន្លះម៉ោងក្រោយមក ខ្លួនបានទូរស័ព្ទទៅឈ្មោះ [redacted] សៀប ដែលត្រូវជាបងបង្កើតរបស់ខ្លួន ថា ឱ្យជួយទូរស័ព្ទទៅឈ្មោះ [redacted] កា ដោយ

សារខ្លួនពុំស្គាល់លេខទូរស័ព្ទឈ្មោះ [redacted] កា ។ នៅពេលដែលបងខ្លួនទូរស័ព្ទទៅកេឈ្មោះ [redacted] កា ពេលនោះ គាត់បានប្រាប់មកខ្លួនថា មានមនុស្សលើកទូរស័ព្ទជំនួសឈ្មោះ [redacted] កា ហើយនិយាយថា ឈ្មោះ [redacted] កា និងឈ្មោះ [redacted] ឡូ បានបុកក្លោងទ្វារទន្លេអុំ ស្លាប់បាត់ហើយ ។ ខ្លួនមិនដែលធ្លាប់មានទំនាស់ជាមួយអ្នកណាទេ។ ហើយខ្លួនក៏ពុំដឹងថាឈ្មោះ [redacted] សុម៉ៃ ឈ្មោះ [redacted] កា និងឈ្មោះ [redacted] ឡូ ធ្លាប់មានទំនាស់ជាមួយអ្នកណាទេ។ ខ្លួនសូមប្តឹងទាមទារសំណងជំងឺចិត្តចំនួន២.៥០០(ពីរពាន់ប្រាំរយ)ដុល្លារអាមេរិក ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីម៉ៅ បានឆ្លើយថា នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ វេលាម៉ោងជិតម៉ោង ៧យប់ ពេលនោះឈ្មោះ [redacted] សឿប បានតេទូរស័ព្ទទៅឈ្មោះ [redacted] ស៊ាប ដែលត្រូវជាឪពុកបង្កើតប្រាប់ថា ឈ្មោះ [redacted] កា និងឈ្មោះ [redacted] ឡូ បានជួបគ្រោះថ្នាក់ចរាចរណ៍ និងស្លាប់បាត់បង់ជីវិតហើយ ។ ពេលនោះដែរឈ្មោះ [redacted] ស៊ាប បានមកប្រាប់ខ្លួនថា កូនរបស់ខ្លួនឈ្មោះ [redacted] ឡូ និងឈ្មោះ [redacted] កា ជាក្មួយរបស់ខ្លួនជួបគ្រោះថ្នាក់ចរាចរណ៍ និងបានស្លាប់ ពេលនោះខ្លួនមិនជឿគេទេ បន្ទាប់មកឈ្មោះ [redacted] សឿប បានប្រាប់ទៀតថា ឈ្មោះ [redacted] ឡូ និងឈ្មោះ [redacted] កា បានជួបគ្រោះថ្នាក់នៅចំណុចក្លោងទ្វាទន្លេអុំ។ ពេលនោះឈ្មោះ [redacted] រ៉ាត់ ត្រូវជាបងថ្លៃខ្លួន បានទៅមើលនៅចំណុចកើតហេតុនោះ ហើយក្រោយមកនៅវេលាម៉ោង ១០យប់ ឈ្មោះ [redacted] រ៉ាត់ បានដឹកយកសពកូនរបស់ខ្លួនមកផ្ទះដើម្បីធ្វើបុណ្យតាមប្រពៃណី។ ខ្លួនពុំដឹងថាកូនរបស់ខ្លួនឈ្មោះ [redacted] ឡូ ធ្លាប់មានទំនាស់ជាមួយអ្នកណាទេ ។ ខ្លួនប្តឹងទាមទារសំណងជំងឺចិត្ត ចំនួន ១០០០០(មួយម៉ឺន)ដុល្លារអាមេរិក ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហួន បានឆ្លើយថា នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ វេលាម៉ោងជិតម៉ោង ៧យប់ ពេលនោះឈ្មោះ [redacted] សឿប បានតេទូរស័ព្ទទៅឈ្មោះ [redacted] ស៊ាប ដែលត្រូវជាឪពុ កបង្កើតរបស់គេប្រាប់ថា ឈ្មោះ [redacted] កា និងឈ្មោះ [redacted] ឡូ បានជួបគ្រោះថ្នាក់ចរាចរណ៍ និងស្លាប់បាត់បង់ជីវិតហើយ។ ពេលនោះឈ្មោះ [redacted] ស៊ាប បានមកប្រាប់ខ្លួនថា កូនរបស់ខ្លួនឈ្មោះ [redacted] កា និងម្នាក់ទៀ តឈ្មោះ [redacted] ឡូ ដែលត្រូវជាក្មួយរបស់ខ្លួន ជួបគ្រោះថ្នាក់ចរាចរណ៍ និងបានស្លាប់។ ពេលនោះខ្លួនមិនជឿគេទេ បន្ទាប់មកឈ្មោះ [redacted] សឿប បានប្រាប់ទៀតថា ឈ្មោះ [redacted] ឡូ និងឈ្មោះ [redacted] កា ជួបគ្រោះថ្នាក់នៅចំណុចក្លោងទ្វាទន្លេអុំ។ បន្ទាប់មកខ្លួនមិនអស់ចិត្តបានឱ្យឈ្មោះ [redacted] កាន ជាកូនរបស់ខ្លួនទៅមើលប្អូនផង បើយ៉ាងម៉េចយកប្អូនទៅពេទ្យមុន កុំចាំម៉ែយូរ បន្ទាប់មកឈ្មោះ [redacted] ណន រស់នៅភូមិជាមួយគ្នាប្រាប់ថា ស្គាល់ក្លោងទ្វារទន្លេដែលជាកន្លែងកើតហេតុ ហើយបានជូនខ្លួនទៅកន្លែងកើតហេតុនោះ។ នៅពេលដែលទៅដល់ចំណុចក្លោងទ្វាទន្លេអុំនោះ ខ្លួនបានឃើញឈ្មោះ [redacted] ឡូ បានដេកស្លាប់គងនឹងថ្ម នៅផ្នែកខាងកើតក្លោងទ្វារទន្លេអុំនោះ ចំណែកកូនខ្លួនបានស្លាប់នៅលើថ្មកម្ពស់ប្រហែលជិត ២ម៉ែត្រ ដោយបានស្លាប់នៅក្បែរគ្នា។ ក្រោយពីខ្លួន និងគ្រួសាររបស់ជនរងគ្រោះទាំងពីរបានទៅដល់កន្លែងកើតហេតុរួចមកក៏ឃើញឈ្មោ[redacted] កា និងឈ្មោ[redacted] ឡូ ស្លាប់នៅនឹងកន្លែងកើតហេតុនោះពិតមែន បន្ទាប់មកសមត្ថកិច្ចបានធ្វើកំណត់សាកសួរ ហើយសមត្ថកិច្ចបានប្រគល់សពឈ្មោះ [redacted] កា មកឱ្យខ្លួន ឯសពឈ្មោះ [redacted] ឡូ បានប្រគល់ឱ្យគ្រួសារដើម្បីធ្វើបុណ្យតាមប្រពៃណី ។ ខ្លួនពុំដឹងថាកូនរបស់ខ្លួនឈ្មោះ [redacted] កា ធ្លាប់មាន

ទំនាស់ជាមួយអ្នកណាទេ ប៉ុន្តែវាមិនដែលទៅដើរលេងនៅពេលយប់ជាមួយអ្នកទេនៅក្នុងភូមិ។ ខ្លួនសូមប្តឹងទាមទារសំណងជំងឺចិត្ត ចំនួន ១០០០០(មួយម៉ឺន)ដុល្លារអាមេរិក ។

- តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] សុខាន បានឆ្លើយថា នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ៦ និង ២៥ នាទីល្ងាច ពេលនោះខ្លួនបានប្រចាំការនៅចំណុចបារ៉ាស់ខាងត្បូងអង្គរតូច ស្រាប់តែឃើញម៉ូតូចំនួន ៣គ្រឿង ម៉ាកហុងដាឌ្រីម មិនចាំពណ៌ មិនចាំផ្លាកលេខ ដោយមិនដឹងថាម៉ូតូមួយគ្រឿងជិះគ្នាប៉ុន្មាននាក់នោះទេ ដោយបានឃើញជិះយ៉ាងលឿន ក្នុងទិសដៅពីត្បូងទៅលិចបាត់ទៅ។ បន្ទាប់មកខ្លួនពុំដឹងថាពួកគាត់ជិះទៅទីណាទៀតនោះទេ។ ក្រោយមកប្រហែលម៉ោង ៦ និង ៣០នាទីល្ងាច ខ្លួនបានទទួលព័ត៌មានពីក្រុមការងារដែលប្រចាំការនៅចំណុចក្លោងទ្វារទន្លេអុំ ក្រុមការងារបានផ្ញើរូបភាពតាម Telegram មកខ្លួន ថាមានគ្រោះថ្នាក់ចរាចរណ៍ ម៉ូតូមួយគ្រឿង ហើយបានស្លាប់មនុស្ស ២នាក់ នៅចំណុចក្លោងទន្លេអុំនោះ តែពុំដឹងថារឿងហេតុការណ៍អ្វីនោះទេ។ ខ្លួនពុំដឹងថាម៉ូតូដែលបានជួបគ្រោះថ្នាក់ចរាចរណ៍នៅចំណុចក្លោងទ្វារទន្លេអុំនោះ ជាម៉ូតូដែលខ្លួនបានឃើញជិះដេញគ្នានៅចំណុចមុខអង្គរតូចនោះទេ ។

- ជនជាប់ចោទឈ្មោះ [redacted] តៅ និងឈ្មោះ [redacted] ស៊ីមែតុង ហៅ តុង អវត្តមានពេលសវនាការ។

## សេចក្តីសន្និដ្ឋានម្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ និងការពិនិត្យឯកសារដែលមាននៅក្នុងសំណុំរឿង ជនជាប់ចោទឈ្មោះ [redacted] គឹមហួរ បានឆ្លើយសារភាពពិតជាបានជិះម៉ូតូដេញវាយជនរងគ្រោះបណ្តាលឲ្យដួលទៅបុកក្លោងទ្វារទន្លេអុំស្លាប់ចំនួន ២នាក់ប្រាកដមែន និងឈ្មោះ [redacted] សុខ បានឆ្លើយបដិសេធពុំបានចូលរួមទេ តែតាមចម្លើយឈ្មោះ [redacted] រតនា បញ្ជាក់ថា ពេលកើតហេតុឈ្មោះ [redacted] សុខ ជិះម៉ូតូតាមឈ្មោះ [redacted] គឹមហួរ ដេញជនរងគ្រោះ ដែលចម្លើយនេះក៏ស៊ីសង្វាក់ទៅនឹងចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ,ចម្លើយសាក្សីផងដែរ ចំណែកជនជាប់ចោទពីរនាក់ទៀតបានគេចខ្លួនបាត់ ឃើញថា មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន ។ ដូច្នេះតំណាងអយ្យការស្នើសុំតម្កល់បទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៦៤អយក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ ទុកជាបានការដដែល និងប្តឹងសុំតុលាការសម្រេចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] តៅ និងឈ្មោះ [redacted] ស៊ីមែតុង ហៅ តុង ព្រមទាំងសម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានរបស់លោក [redacted]
## មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សុខ

តាមសវនាការនេះជនជាប់ចោទឈ្មោះ [redacted] សុខ បានឆ្លើយបដិសេធដោយខ្លួនគេពុំបានចូលរួមប្រព្រឹត្តទេ ,ឈ្មោះ [redacted] គឹមហួរ បានឆ្លើយថា ឈ្មោះ [redacted] ស៊ីម៉ែតុង ត្រូវបានគេឌឺគាត់ ទើបគាត់ជិះម៉ូតូដេញតាមបណ្តាលឲ្យជនរងគ្រោះដួលទៅបុកនឹងក្លោងទ្វារទន្លេអុំស្លាប់អស់ចំនួន ២នាក់។ ជាក់ស្តែងគាត់ពុំបានឃើញឈ្មោះ [redacted] សុខ ទៅជាមួយគាត់ទេ ហេតុនេះស្នើសុំតុលាការសម្រេចឲ្យកូនក្តីខ្លួនរួចខ្លួនពីបទចោទ ។



Scanned with CamScanner

**សេចក្ដីសន្និដ្ឋានរបស់លោក [redacted] មេធាវីការពារសិទ្ធិឲ្យ**
**ជនជាប់ចោទឈ្មោះ [redacted] ស៊ីមែតុង ,ឈ្មោះ [redacted] តៅ និងឈ្មោះ [redacted] គឹមហួរ**

តាមការសួរដេញដោលពេលសវនាការឃើញថា កូនក្ដីខ្លួនឈ្មោះ [redacted] គឹមហួរ ទទួលស្គាល់កំហុសរបស់ខ្លួន គាត់មានការស្ដាយក្រោយជាខ្លាំង ហេតុនេះស្នើសុំតុលាការជួយសម្រាលទោសដល់គាត់ដោយអនុគ្រោះ ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] តៅ គឺគាត់គ្រាន់តែជិះម៉ូតូទៅតែប៉ុណ្ណោះ ,គាត់ពុំមានចេតនាក្នុងការប្រព្រឹត្តទេ ហើយគាត់ក៏ពុំបានសម្រួល ឬផ្ដល់ស្ថានភាអរអ្វីនោះទេ។ រីឯឈ្មោះ [redacted] ស៊ីម៉ែតុង គាត់អវត្តមានពុំបានឆ្លើយដោះបន្ទុកទេ ប្រសិនបើគាត់បានប្រព្រឹត្តមែននោះសូមតុលាការពិចារណាអំពីកូនក្ដីខ្លួនជាអនីតិជន ដោយសារតែគាត់សេពគប់មិត្តភក្ដិខុស ហេតុនេះស្នើសុំតុលាការផ្ដល់ស្ថានសម្រាលទោសដល់គាត់ដោយអនុគ្រោះ ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

- ជនជាប់ចោទឈ្មោះ [redacted] គឹមហួរ បានសំណូមពរថា សូមតុលាការមេត្តាជួយសម្រាលទោសដល់ខ្លួនដោយអនុគ្រោះ ។

- ជនជាប់ចោទឈ្មោះ [redacted] សុខ បានសំណូមពរថា សូមតុលាការមេត្តាជួយរកយុត្តិធម៌ដល់ខ្លួនផង ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។

ក្រោយពីបាន ស្ដាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបាន ស្ដាប់ចម្លើយជនរងគ្រោះ ,ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

ក្រោយពីបាន ស្ដាប់អំណានជនរងគ្រោះ និងអំណាន់ចម្លើយសាក្សី

ក្រោយពីបាន ស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបាន ស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបាន ស្ដាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យ និងពិភាក្សាត្រឹមត្រូវតាមច្បាប់

## <u>សំអាងហេតុ</u>

១- តុលាការបានទទួលជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១១៧៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ លេខ: ៥៩៦ពស.ព្រស/ឈ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ដែលបានបញ្ជូនជនជាប់ចោទ៖

ក.ឈ្មោះ [redacted] គឹមហួរ ភេទប្រុស កើតថ្ងៃទី០១ ខែសីហា ឆ្នាំ២០០១ ជនជាតិខ្មែរ ។

ខ. ឈ្មោះ [redacted] សុខ ភេទប្រុស កើតនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៥ ជនជាតិខ្មែរ ។

គ. ឈ្មោះ [redacted] តៅ ភេទប្រុស កើតនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៤ ជនជាតិខ្មែរ ។

ឃ. ឈ្មោះ [redacted] ស៊ីមែតុង ហៅ តុង ភេទប្រុស កើតនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៧ ជនជាតិខ្មែរ។



Scanned with CamScanner

មកជំនុំជម្រះពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅចំណុចក្លោងទ្វារទន្លេអុំ ស្ថិតនៅភូមិក្រវ៉ាន់ សង្កាត់នគរធំ ខេត្តសៀមរាប កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ។

២- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] គឹមហួរ នាពេលសវនាការ ជនជាប់ចោទបានឆ្លើយសារភាពហើយ សកម្មភាពរបស់ជនជាប់ចោទអាចឲ្យតុលាការជឿបានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន ចម្លើយនេះមានភាពស៊ីសង្វាក់ទៅនឹងអង្គហេតុ ព្រមទាំងឯកសារនានាដែលមាននៅក្នុងសំណុំរឿងនាំឲ្យកំណត់បានថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] គឹមហួរ គឺជាបទល្មើស ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ដូចការបញ្ជូនសំណុំរឿងមកជំនុំជម្រះរបស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ពិតប្រាកដមែន ។

៣- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខ នាពេលសវនាការ ជនជាប់ចោទបានឆ្លើយបដិសេធចំពោះការចោទប្រកាន់ ឃើញថា គ្រាន់តែជាចម្លើយដោះសារ ដើម្បីគេចវេះពីការទទួលខុសត្រូវព្រហ្មទណ្ឌលើអំពើល្មើសរបស់ខ្លួនតែប៉ុណ្ណោះ ពុំមានភស្តុតាងជាមូលដ្ឋានអាចឲ្យតុលាការជឿជាក់បាននោះទេ ផ្ទុយទៅវិញផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខ នៅដំណាក់កាលមន្រ្តីនគរបាលយុត្តិធម៌ ជនជាប់ចោទបានឆ្លើយសារភាពអស់ហើយ ហើយចម្លើយនេះក៏មានភាពស៊ីសង្វាក់នឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] គឹមហួរ ផងដែរ ឃើញថា នៅថ្ងៃកើតហេតុជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ដូចការបញ្ជូនមកជំនុំជម្រះរបស់របស់ចៅក្រមស៊ើបសួរពិតប្រាកដមែន ។

៤- តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] សុម៉ៃ ,ឈ្មោះ [redacted] សាយ ,ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីម៉ៅ ,ឈ្មោះ [redacted] សុខាន និងចម្លើយសាក្សីឈ្មោះ [redacted] ហួន បានឆ្លើយប្រហាក់ប្រហែលគ្នានៅគ្រប់ដំណាក់កាល ហើយចម្លើយនេះក៏មានភាពស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] គឹមហួរ និងឈ្មោះ [redacted] សុខ ថា កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ៦ និង ៣០នាទី ខ្លួន និងបីនាក់ផ្សេងទៀត បានជិះម៉ូតូដល់ចំណុចខាងត្បូងកស្សិណអង្គរ ត្រង់រង្វង់មូលបានបត់ទៅទិសខាងកើតចំណុចផ្លូវកែវ ស្រាប់តែមានម៉ូតូ២គ្រឿង ឌុបគ្នាម្នាក់មួយគ្រឿង បានយកមួកសុវត្ថិភាពវាយទៅលើឈ្មោះ [redacted] កា ចំកខាងឆ្វេងបណ្តាលឲ្យដួលម៉ូតូរបស់ឈ្មោះ [redacted] កា ហើយឈ្មោះ [redacted] កា បែកក្បាល និងបណ្តាលឲ្យបែកអាវម៉ូតូខាងឆ្វេង និងវៀចចង្កឹះលេខម៉ូតូ បន្ទាប់មកខ្លួន និងឈ្មោះ [redacted] សាយ បានជួយលើកម៉ូតូដែលដួលនោះ ហើយឈ្មោះ [redacted] ឡូ បានពត់ចង្កឹះលេខម៉ូតូ ពេលនោះក្រុមម៉ូតូដែលបានវាយឈ្មោះ [redacted] កា នោះ បានជិះត្រឡប់មកវិញ ហើយពួកវាបានស្រែកថា ដេញកាប់ពួកវាទៅ ពេលនោះខ្លួន និងឈ្មោះ [redacted] សាយ ភ័យខ្លាំងពេកក៏បានជិះម៉ូតូ គេចរៀងៗខ្លួនយ៉ាងលឿន ហើយខ្លួនឌុបឈ្មោះ [redacted] សាយ ទៅចូលកន្លែងជាងជួសជុលម៉ូតូ ចំណែកឈ្មោះ [redacted] កាយ និងឈ្មោះ [redacted] ឡូ ខ្លួនពុំដឹងថា ពួកវាជិះម៉ូតូទៅទីណាទេ បានមួយសន្ទុះក្រោយមកឈ្មោះ [redacted] សៀប បានប្រាប់ទៅឈ្មោះ [redacted] សាយ

ថា មានមនុស្សស្រីលើកទូរស័ព្ទរបស់ឈ្មោះ [redacted] កា ហើយនិយាយថា ឈ្មោះ [redacted] កា និងឈ្មោះ [redacted] ឡូ បានបុកក្លោងទ្វារទន្លេអុំស្លាប់នៅនឹងកន្លែងកើតហេតុបាត់ហើយ ។

៥- តាមសេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការនាពេលសវនាការ តុលាការយល់ឃើញថា សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការមានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីបញ្ជាក់ពីតម្រុយពិរុទ្ធភាពរបស់ជនជាប់ចោទ តុលាការនឹងសម្រេចអំពីបញ្ហានេះតាមច្បាប់ ។

៦- តាមសំបុត្រមរណភាព លេខ ១៨ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំរើល ស្រុកពួក ខេត្តសៀមរាប បានបញ្ជាក់ថា ឈ្មោះ [redacted] កា បានទទួលមរណភាពនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ និងសំបុត្រមរណភាព លេខ ១៩ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំរើល ស្រុកពួក ខេត្តសៀមរាប បានបញ្ជាក់ថា ឈ្មោះ [redacted] ឡូ បានទទួលមរណភាពនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ ពិតប្រាកដមែន ។

៧- សកម្មភាពរបស់ជនជាប់ចោទ ត្រូវបានច្បាប់កំណត់ថា ជាបទល្មើស **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ** ហើយច្បាប់បានចែង និងបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ ដាក់ពន្ធនាគារពី **៧(ប្រាំពីរ)ឆ្នាំ ទៅ ១៥(ដប់ប្រាំ)ឆ្នាំ** ។

៨- អំពើរបស់ជនជាប់ចោទធ្វើឲ្យប៉ះពាល់ដល់បូរណភាពនៃបុគ្គល ,ប៉ះពាល់ដល់សន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ របៀបរៀបរយល្អក្នុងសង្គមដែលច្បាប់ហាមឃាត់ ជាពិសេសបានបំពានទៅនឹងមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ ។

៩- ជនជាប់ចោទឈ្មោះ [redacted] គឹមហួរ ជា នីតិជន ដែលមានសមត្ថភាពស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ។

១០- ជនជាប់ចោទឈ្មោះ [redacted] សុខ កើតនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៥ ,ឈ្មោះ [redacted] តៅ កើតនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៤ និងឈ្មោះ [redacted] ស៊ីមែតុង ហៅ តុង កើតនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៧ បើគិតមកដល់ថ្ងៃដែលជនជាប់ចោទប្រព្រឹត្តបទល្មើស ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ ជនជាប់ចោទ ជាអនីតិជន ប៉ុន្តែជនជាប់ចោទមានសមត្ថភាពស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត។ ដូចនេះ តុលាការគប្បីសម្រេចផ្ដន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សុខ ,ឈ្មោះ [redacted] តៅ និងឈ្មោះ [redacted] **ស៊ីមែតុង ហៅ តុង** ទៅតាមច្បាប់ ដោយស្របតាមបញ្ញត្តិមាត្រា១៦០(មូលទោសអនុវត្តចំពោះអនីតិជនចាប់ពី ១៤ឆ្នាំ ឡើងទៅ ) នៃក្រមព្រហ្មទណ្ឌ ។

១១- មានបន្ទុក និងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] គឹមហួរ ភេទប្រុស កើតថ្ងៃទី០១ ខែសីហា ឆ្នាំ២០០១ ជនជាតិខ្មែរ ,ឈ្មោះ [redacted] សុខ ភេទប្រុស កើតនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៥ ជនជាតិខ្មែរ,ឈ្មោះ [redacted] តៅ ភេទប្រុស កើតនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៤ ជនជាតិខ្មែរ,ឈ្មោះ [redacted] ស៊ីមែតុង ហៅ តុង ភេទប្រុស កើតនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៧ ជនជាតិខ្មែរ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅចំណុចក្លោងទ្វារទន្លេអុំ ស្ថិតនៅភូមិក្រាំង



Scanned with CamScanner

សង្កាត់នគរធំ ខេត្តសៀមរាប កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ។

១២-ជនជាប់ចោទឈ្មោះ [redacted] តៅ និងឈ្មោះ [redacted] ស៊ីមែតុង ហៅ តុង បានរត់គេចខ្លួន ក្រោយពីប្រព្រឹត្តបទល្មើសរួច ហើយម៉្យាងទៀតតុលាការនឹងប្រកាសផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារ១(មួយ) ឆ្នាំយ៉ាងតិច ដោយគ្មានការព្យួរទេ ដូចនេះ តាមបញ្ញត្តិមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តាមសេចក្តីសម្រេចពិសេស តុលាការគប្បីចេញនៅក្នុងពេលសវនាការនូវដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទអវត្តមាន។

១៣- ឈ្មោះ [redacted] សុម៉ៃ ជាដើមបណ្តឹងរដ្ឋប្បវេណី បានប្តឹងទាមទារសំណងជម្ងឺចិត្តជាប្រាក់ចំនួន ២៥០០(ពីរពាន់ប្រាំរយ)ដុល្លារអាមេរិក គប្បីតុលាការនឹងលើកយកមកពិចារណាតាមសភាពជាក់ស្តែង។

១៤- ឈ្មោះ [redacted] សាយ ជាដើមបណ្តឹងរដ្ឋប្បវេណី បានប្តឹងទាមទារសំណងជម្ងឺចិត្តជាប្រាក់ចំនួន ២៥០០(ពីរពាន់ប្រាំរយ)ដុល្លារអាមេរិក គប្បីតុលាការនឹងលើកយកមកពិចារណាតាមសភាពជាក់ស្តែង។

១៥- ឈ្មោះ [redacted] ស្រីម៉ៅ ជាដើមបណ្តឹងរដ្ឋប្បវេណី បានប្តឹងទាមទារសំណងជម្ងឺចិត្តជាប្រាក់ចំនួន ១០០០០(មួយម៉ឺន)ដុល្លារអាមេរិក គប្បីតុលាការនឹងលើកយកមកពិចារណាតាមសភាពជាក់ស្តែង។

១៦- ឈ្មោះ [redacted] ហួន ជាដើមបណ្តឹងរដ្ឋប្បវេណី បានប្តឹងទាមទារសំណងជម្ងឺចិត្តជាប្រាក់ចំនួន ១០០០០(មួយម៉ឺន)ដុល្លារអាមេរិក គប្បីតុលាការនឹងលើកយកមកពិចារណាតាមសភាពជាក់ស្តែង។

## ហេតុដូច្នេះ សម្រេច

**១/- ផ្តន្ទាទោស ៖**

ក.ឈ្មោះ [redacted] **គឹមហួរ** ភេទប្រុស កើតថ្ងៃទី០១ ខែសីហា ឆ្នាំ២០០១ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល **៩(ប្រាំបួន)ឆ្នាំ** ។

បទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ** ប្រព្រឹត្តនៅចំណុចក្លោងទ្វារទន្លេអុំ ស្ថិតនៅភូមិក្រវ៉ាន់ សង្កាត់នគរធំ ខេត្តសៀមរាប កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ។

ខ.ឈ្មោះ [redacted] **សុខ** ភេទប្រុស កើតនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៥ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល **៤(បួន)ឆ្នាំ** ។

គ- ឈ្មោះ [redacted] **តៅ** ភេទប្រុស កើតនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៤ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល **៤(បួន)ឆ្នាំ** ។

ឃ- ឈ្មោះ [redacted] **ស៊ីមែតុង ហៅ តុង** ភេទប្រុស កើតនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៧ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល **៤(បួន)ឆ្នាំ** ។

ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ** ប្រព្រឹត្តនៅចំណុចក្លោងទ្វារទន្លេអុំ ស្ថិតនៅភូមិក្រវ៉ាន់ សង្កាត់នគរធំ ខេត្តសៀមរាប កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២២៤ និងមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

២/- ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] តៅ និងឈ្មោះ [redacted] ស៊ីមែតុង ហៅ តុង ដើម្បីយកមកអនុវត្តទោសតាមអំណាចនៃសាលក្រមនេះ តាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣/-បង្គាប់ឲ្យឈ្មោះ [redacted] គឹមហួរ ,ឈ្មោះ [redacted] សុខ ,ឈ្មោះ [redacted] តៅ និងឈ្មោះ [redacted] ស៊ីមែតុង ហៅ តុង រួមគ្នាសងសំណងជម្ងឺចិត្តទៅ៖

ក.ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុម៉ៃ ជាប្រាក់ចំនួន ៦.000.000(ប្រាំមួយលាន)រៀល។

ខ.ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាយ ជាប្រាក់ចំនួន ៦.000.000(ប្រាំមួយលាន)រៀល។

គ.ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីម៉ៅ ជាប្រាក់ចំនួន ៣0.000.000(សាមសិបលាន)រៀល។

ឃ. ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហួន ជាប្រាក់ចំនួន ៣0.000.000(សាមសិបលាន)រៀល។

ការទាមទារលើសពីនេះ បដិសេធចោល ។

សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] គឹមហួរ ,ឈ្មោះ [redacted] សុខ និងចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាយ ,ឈ្មោះ [redacted] ស្រីម៉ៅ និងឈ្មោះ [redacted] ហួន និងកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុម៉ៃ ,កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] តៅ និងជនជាប់ចោទឈ្មោះ [redacted] ស៊ីមែតុង ហៅ តុង ។

ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃ ព្រហស្បតិ៍ ១កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៦
សៀមរាប , ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣
ក្រឡាបញ្ជី

[redacted]

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានថតចម្លងត្រឹមត្រូវចេញពី
ច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី
សៀមរាប ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០២៣
ក្រឡាបញ្ជី

[redacted]



Scanned with CamScanner